**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លេខ៖.........✓.............អ.ជ.ប.ជ.អ.

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥
# ថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩
# ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥បានដំណើរការរយៈពេលមួយព្រឹកពេញ នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥ នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល មានចំនួនសរុប១៨០រូប។

កិច្ចប្រជុំបានថ្លែងអំណរគុណ និងកោតសរសើរចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងបន្តចូលរួមយ៉ាងសកម្មក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥ បានដាក់ចេញនូវការសម្រេចចិត្ត ដូចតទៅ៖

១- គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍបន្តចូលរួមអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា។

២- ក្រុមការងារចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ត្រូវ៖

- ពិនិត្យរៀបចំកែសម្រួលយុទ្ធសាស្ត្រពហុវិស័យ ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ក្នុងស្ថានភាពនៃការធ្លាក់ចុះហិរញ្ញប្បទានពីខាងក្រៅ។
- ពង្រឹងយន្តការសម្របសម្រួលដែលមានស្រាប់ ដើម្បីកៀរគរធនធានពីដៃគូអភិវឌ្ឍសម្រាប់បំពេញបង្គ្រប់ថវិកាដែលបានកាត់ពីកញ្ចប់ថវិកាមូលនិធិសកលឆ្នាំ២០២៤-២០២៦។

៣- ដាក់ខេត្តកំពង់ស្ពឺ និងខេត្តតាកែវជាខេត្តពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។



អាសយដ្ឋាន៖ អគារលេខ១៦ ផ្លូវលេខ២៧១កែង១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក ទូរស័ព្ទលេខ០៧៧ ៩៣៣ ៥៥៩ និង ០៨៦ ៦៣០ ៥៦៤
Tel: (855) 77 933 559 / 86 630 564 • E-mail: info@naaa.gov.kh • Website: www.naaa.gov.kh

៤- ក្រុមការងារផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ទាំង៥ក្រុម បន្តដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ដើម្បីសម្រេចគោលដៅដែលបានកំណត់។

៥- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជំរុញការបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តសារាចរអន្តរក្រសួងលេខ០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

៦- ក្រសួងអប់រំ យុវជន និងកីឡាបង្កើនការផ្សព្វផ្សាយអំពីរបៀបបង្ការការឆ្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ និងកាត់បន្ថយការមាក់ងាយរើសអើងចំពោះអ្នកជំងឺអេដស៍ និងប្រជាជនគន្លឹះ ដល់បុគ្គលិកអប់រំ សិស្ស និស្សិត និងក្រុមកីឡាករ កីឡាការិនីឱ្យបានទូលំទូលាយ។

៧- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បន្តជំរុញឡើងនូវស្នាដៃអប់រំរឿងឈុតខ្លីៗដើម្បីបញ្ជ្រាបសារស្តីពីការបង្ការ ការទប់ស្កាត់ និងការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ និងណែនាំដល់ផលិតករខារ៉ាអូខេ ឱ្យដាក់ខ្លឹមសារអប់រំស្តីពីការចម្លងមេរោគអេដស៍និងជំងឺអេដស៍ ដោយរត់អក្សរខាងក្រោមពេលចាក់បញ្ចាំង។

៨- ក្រសួងព័ត៌មានបន្តគាំទ្រនិងជំរុញការផ្សព្វផ្សាយសារអប់រំ រឿងអប់រំខ្លីៗ ផលិតមាតិកាអប់រំថ្មីៗ និងបង្កើតវេទិកាពិភាក្សាអំពីរបៀបបង្ការការឆ្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ ជាពិសេស ម=ម និងកាត់បន្ថយការមាក់ងាយរើសអើងចំពោះអ្នកជំងឺអេដស៍និងប្រជាជនគន្លឹះឱ្យបានញឹកញាប់និងជាប់ជាប្រចាំ។

៩- គ្រប់រដ្ឋបាលរាជធានី ខេត្តត្រូវគាំទ្ររៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានចប់សព្វគ្រប់១០០% នាដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៥។

១០- រដ្ឋបាលរាជធានី ខេត្តស្វែងរកការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធជំរុញគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណ ម.ស.ស. ដល់ប្រជាជនគន្លឹះដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ ទាំងស្ត្រី(EW) បុរសរួមភេទជាមួយបុរស (MSM) និងអ្នកបំប្លែងភេទ(TG)ឱ្យបានលើសពី៥០%នៅដំណាច់ឆ្នាំ២០២៥ និងសហការជាមួយអង្គការសង្គមស៊ីវិលនិងបណ្តាញជាដៃគូ ខិតខំផ្សព្វផ្សាយទាក់ទាញប្រជាជនគន្លឹះមកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគ និងប្រើប្រាស់សេវាបង្ការការឆ្លងមេរោគអេដស៍នានា។

១១- ក្រសួងសុខាភិបាលបន្តពង្រីកសេវាធ្វើតេស្តរកមេរោគអេដស៍ សេវាផ្តល់ឱសថPrEP( ឱសថបង្ការមុនពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ) និងPEP( ឱសថបង្ការក្រោយពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ) និងបង្កើនការរកបាន និងការប្រើប្រាស់ស្រោម

អនាម័យឱ្យមានប្រសិទ្ធភាព និងជាប់លាប់ដល់ក្រុមគោលដៅ ព្រមទាំងពង្រឹងការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ពីមាតាទៅទារក។

១២- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ និងបញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ខេត្តព្រះសីហនុ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥

**ប្រធានអង្គប្រជុំ**

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**